# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ថ្មស
## រយៈពេល ៣ឆ្នាំ ( កញ្ញា ២០២៥ - សីហា ២០២៨ )

**ឈ្មោះសហគមន៍នេសាទ ៖ ថ្មស**

ភូមិ ៖ ចម្លងគោ ថ្មស ស្រែត្រាវ ស្រែថ្មី និងចំការលើ

ឃុំ ៖ ថ្មស

ស្រុក ៖ បូទុមសាគរ

ខេត្ត ៖ កោះកុង

---

រៀបចំដោយរដ្ឋបាលជលផលសហការជាមួយខណ្ឌរដ្ឋបាលជលផលកោះកុង( គម្រោងជលផលសមុទ្រនិងតំបន់ឆ្នេរប្រកបដោយចីរភាព)

## មាតិកា
## ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ


**១- ស្ថានភាពទូទៅ**.......................................................................................................................១

**២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**.......................................................................................២

ក- ប្រជាពលរដ្ឋ.............................................................................................................................២

ខ-មុខរបរ......................................................................................................................................៣

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងសហគមន៍នេសាទ**..............................៣

ក- ទីតាំង.....................................................................................................................................៣

ខ- ដែននេសាទ...............................................................................................................................៣

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្សជលផល.........................................................................៤

ឃ- ធនធានជលផល.........................................................................................................................៤

**៤- ការធ្វើនេសាទ**............................................................................................................................៤

ក- អ្នកនេសាទ...............................................................................................................................៤

ខ- ឧបករណ៍នេសាទ........................................................................................................................៤

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ.................................................................................................៦

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**..............................................................................................៧

**ក- ទស្សនៈវិស័យ**.........................................................................................................................៧

**ខ- គោលបំណង**...........................................................................................................................៧

**គ-ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ**.........................................................................................៧

**ផ្នែកទី១.ការអភិបាលកិច្ចនិងការគ្រប់គ្រង**.........................................................................................៧

គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ.................................................................................៧

គ២- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ...............................៨

គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល.........................................................................................៩

គ៤- ផែនការប្រើប្រាស់ឧបករណ៍នេសាទ............................................................................................១០

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល..........................................................................................១១

គ៦- ផែនការកែលម្អកន្លែងសហគមន៍នេសាទ....................................................................................១២

គ៧- ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ.............................................១៣

គ៨- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ.......................................១៤

គ៩- ផែនការគ្រប់គ្រងព្រៃកោកាង....................................................................................................១៤

**ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ**........................................................................១៥

គ១០- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ.................................................................១៥

គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ.........................................................................១៧

គ១២- ផែនការបង្កើតតំបន់ទេសចរណ៍ជលផលរបស់សហគមន៍នេសាទ.....................................................១៨

គ១៣- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ............................................................................១៩

ផ្នែកទី៣. **ការចូលរួមរបស់ស្ត្រីនិងយុវជន ការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ**....................២០
គ១៤- ផែនការផ្សព្វផ្សាយនិងជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិកសហគមន៍នេសាទ...........២០
គ១៥- ផែនការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ.........................................២០
**ផ្នែកទី៤. ការទំនាក់ទំនងនិងគៀងគរធនធាន**.................................................................២១
គ១៦-ផែនការទំនាក់ទំនងនិងគៀងគរធនធាន.........................................................២១
គ១៧- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍..........................................២២
**ឃ. ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**...............................................................២២
**ង. ផែនការយុទ្ធសាស្ត្រ**..............................................................................................២៣
**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បែកក្រង់ រយៈពេល៣ឆ្នាំ**...................២៤
**តារាងពេលវេលាការងារ**.......................................................................................៣២

# ផែនការគ្រប់គ្រង
# តំបន់សហគមន៍នេសាទ

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទថ្មស បានធ្វើមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ នៅឆ្នាំ២០០៥ និងបានបោះឆ្នោតអាណត្តិទី៤ ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣។ បានចុះបញ្ជីជាផ្លូវការទទួលស្គាល់ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយប្រកាសលេខ៦២៨ ប្រក.កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

សហគមន៍នេសាទថ្មស ស្ថិតនៅភូមិចម្លងគោ ថ្មស ស្រែត្រាវ ស្រែថ្មី និងចំការលើ ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង។ សហគមន៍នេសាទនេះ មានសមាជិកសរុបចំនួន៦០០នាក់ ស្រី២៣០នាក់ ក្នុងនោះមានគ្រួសារសរុបចំនួន៣០០គ្រួសារ។ មានគណៈកម្មការចំនួន១១នាក់ ស្រី២នាក់ និងមានក្រុមល្បាតចំនួន១០នាក់ ។

កន្លងមកសហគមន៍នេសាទថ្មស បានរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងតំបន់សហគមន៍នេសាទ បានកំណត់ព្រំប្រទល់ផែនទីតំបន់សហគមន៍នេសាទ បានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ដោយបានបែងចែកតួនាទី និងភារកិច្ចការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ មានការទទួលស្គាល់ឯកភាពពីភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិ និងអាជ្ញាធរមូលដ្ឋាន។ ការអនុវត្តផែនការគ្រប់គ្រងតំបន់សហគមន៍នេសាទ គណៈកម្មការ និងសមាជិកសហគមន៍នេសាទបានសហការជាមួយដៃគូពាក់ព័ន្ធ ដោយបានអនុវត្តសកម្មភាពសំខាន់ៗ រួមមានការចូលរួមប្រជុំ និងបិទផ្សាយផែនទីតំបន់សហគមន៍នេសាទ រៀបចំតំបន់អភិរក្សជលផលរបស់សហគមន៍នេសាទ បង្កើតធនាគារក្តាមសេះសាកល្បងដើម្បីបង្កើនផលស្តុកក្តាមសេះក្នុងធម្មជាតិ ផ្តួចផ្តើមសកម្មភាពមុខរបរកែច្នៃផលនេសាទ វារីវប្បកម្ម ចូលរួមយុទ្ធនាការផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពនានា រៀបចំក្រុមល្បាត និងចុះល្បាតដោយសហការជាមួយសមត្ថកិច្ចជលផល អាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលកើតមានក្នុងតំបន់សហគមន៍នេសាទ។សកម្មភាពទាំងនេះសបញ្ជាក់ពីការប្រឹងប្រែងអនុវត្តសកម្មភាពស្របតាមផែនការគ្រប់គ្រងរបស់ខ្លួនទៅតាមធនធានដែលមានកំណត់។ បច្ចុប្បន្នសហគមន៍នេសាទថ្មស កំពុងខិតខំតៀងគរ ការចូលរួមធនធាន និងការគាំទ្រនានាក្នុងការដោះស្រាយបញ្ហាប្រឈមដែលនៅតែកើតមាន ឡើងដូចខាងក្រោម៖

- ផលនេសាទថយចុះបណ្តាលពីសកម្មភាពនេសាទលើសកម្រិត ការនេសាទដោយប្រើប្រាស់លបកន្ទុយកណ្តុរតម្រូវការកើនឡើង ការប្រើឧបករណ៍នេសាទបំផ្លិចបំផ្លាញ មានដូចជាទូកអូសស្រទាប់បាតនៅទឹករាក់ ការប្រើប្រាស់ជាដើម ព្រមទាំងការប្រជែងគ្នាក្នុងការនេសាទរវាងសកម្មភាពនេសាទខ្នាតតូច នេសាទជាប្រពៃណី និងនេសាទខ្នាតធំ។ សហគមន៍នេសាទសង្កេតឃើញថាបញ្ហានេះបានជះឥទ្ធិពលដល់ផលចាប់ត្រី និងវារីសត្វសមុទ្រផ្សេងៗ មានការថយចុះ
- ការថយចុះប្រព័ន្ធអេកូស៊ីស្ទែមជលផលសមុទ្រ ដូចជាជម្រកជលផលសមុទ្រ ព្រៃកោងកាង ដែលកំពុងរងផលប៉ះពាល់ពីការនេសាទដែលបំផ្លិចបំផ្លាញ ការប្រើប្រាស់ដីមិនសមស្របជាដើម
- សមត្ថភាពនិងចំណេះដឹងរបស់គណៈកម្មការ និងសមាជិកនៅមានកម្រិត ដូចជា ខ្វះជំនាញបច្ចេកទេសលើការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងខ្វះការអនុវត្តការងារគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋាន ឬសហគ្រប់គ្រងនៅមានកម្រិត
- ការជ្រើសរើសមុខរបរមានកម្រិត និងងាយរងគ្រោះ ដោយពឹងផ្អែកលើប្រភពចំណូលតែមួយ និងផលចាប់ពីធម្មជាតិ អស្ថេរភាពតម្លៃលិតផលកសិកម្មដែលកំណត់ដោយឈ្មួញកណ្តាលក្នុងតំបន់ ពិបាកក្នុងការទទួល

បានតម្លៃបន្ថែមលើផលផលិតផលដោយសារគុណភាពផលិតផលនិងការកែច្នៃ ខ្វះទន់ក្នុងការចាប់ផ្ដើម និងជំនាញលើមុខរបរ ដូចជាការបង្កើតសេវាទេសចរណ៍ជលផល វារីវប្បកម្មដែលមិនប្រើចំណីជាដើម

- ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិដែលប៉ះពាល់លើការប្រកបរបរនេសាទ សេវាទេសចរណ៍ជលផល លំនៅដ្ឋាននិងគុណភាពទឹកសមុទ្រ ដូចជាកំណើនជាតិពុលក្នុងទឹក កំដៅទឹកសមុទ្រអាចនឹងប៉ះពាល់ដល់ទេសចរណ៍ជលផល និងវារីវប្បកម្ម
- ការចោលសំរាម ផ្លាស្ទីក និងកាកសំណល់នានាដែលនាំឱ្យប៉ះពាល់ដល់គុណភាពទឹកសមុទ្រ បង្កឱ្យមានជាតិពុល និងសោភណ្ឌភាពនៅក្នុងសហគមន៍នេសាទ
- សមត្ថភាពរបស់គណៈកម្មការសហគមន៍នេសាទនៅមានកម្រិត ដូចជាការងាររដ្ឋបាល ការអនុវត្តសកម្មភាព ការងារគ្រប់គ្រង ការងារសេដ្ឋកិច្ច ការការពារធនធានជលផល និងសកម្មភាពការងារល្បាត
- លទ្ធភាពចូលរួមអនុវត្តច្បាប់មានកម្រិត ដោយខ្វះមធ្យោបាយ ដូចជាឧករណ៍ទំនាក់ទំនងរាយការណ៍ ទូកល្បាតដែលធននឹងអាកាសធាតុ ប្រភពថវិកាគាំទ្រសកម្មភាពល្បាត ការចូលរួមពីសមាជិកមានកម្រិត ការផ្សព្វផ្សាយច្បាប់ស្ដីពីជលផលមិនបានដិតដល់ជាប្រចាំ។

ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទថ្មស ខែកុម្ភៈ ឆ្នាំ២០២២ ដល់ ខែធ្នូ ឆ្នាំ២០២៤ លេខ៦២៨ ជផ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ត្រូវបានហួសសុពលភាព ដូច្នេះសហគមន៍នេសាទថ្មស ត្រូវធ្វើផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ ឡើងវិញ ដោយធ្វើបច្ចុប្បន្នភាពនូវទិន្នន័យសហគមន៍នេសាទ សកម្មភាពនានា ស្របនឹងនិន្នាការថ្មីៗ តម្រូវការសហគមន៍ និងការប៉ាន់ប្រមាណថវិកា ដោយផ្ដោតលើការអភិរក្សជលផល ការ បង្កើតមុខរបរ ការគ្រប់គ្រងសកម្មភាពនេសាទនិងការប្រើប្រាស់ធនធានជលផលនៅក្នុងសហគមន៍នេសាទប្រកបដោយនិរន្តរភាព និងការចូលរួមចំណែកកាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ស្របតាមប្រការ៣០ នៃប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ ស្ដីពីគោលការណ៍ណែនាំសហគមន៍នេសាទ។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

- ប្រជាពលរដ្ឋសរុបក្នុងតំបន់មានចំនួន៩០៩០នាក់ ស្រី ៤៩៩២ នាក់ ក្នុងនោះមានចំនួន ២២១៣ គ្រួសារ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ៩៩% សាសនាយាស៊ូ១%។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរ ៤៩៤ នាក់ ស្រី ២៥១ នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន ២៥៨៩ នាក់ ស្រី ១៣៧៦ នាក់ កម្រិតវិទ្យាល័យចំនួន ១៣៥ នាក់ ស្រីចំនួន ៨៩នាក់ និងកម្រិតឧត្ដម៣០នាក់ ។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន៥៧នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន៤៣នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន៣៦នាក់ ស្រី១៧នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន៣៦នាក់ ស្រី១៧នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន៣០នាក់ ស្រី២០នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន៤នាក់ ស្រី៣នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមានៈ

- ធ្វើនេសាទចំនួន ១៦៦០គ្រួសារ
- ដឹកជញ្ជូនផលនេសាទ ៧គ្រួសារ
- កែច្នៃផលិតផលជលផល ៨៥ គ្រួសារ (បង្គាក្រៀម ក្តាមប្រៃ និងត្រីងៀត)
- អ្នកជួសជុលឧបករណ៍នេសាទ ១២គ្រួសារ
- ជាងជួសជុលទូក ៦គ្រួសារ
- អ្នកដឹកជញ្ជូនភ្ញៀវ ៩គ្រួសារ
- ចិញ្ចឹមសត្វ ៣០គ្រួសារ
- ជាងសំណង់ ៣៥គ្រួសារ
- អ្នកលក់ដូរ ៣៣២គ្រួសារ
- ជាងជួសជុលម៉ូតូ ១៨គ្រួសារ
- កម្មករ ៣៥គ្រួសារ

ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៨ ០០០ ០០០ រៀល ។

## ៣ កន្លែងសហគមន៍នេសាទ និងធនធានដែលមាននៅក្នុងកន្លែងសហគមន៍នេសាទ

**ក. ទីតាំង**

កន្លែងសហគមន៍នេសាទថ្មស មានកន្លែងនេសាទតាមឆ្នេរ វាលភក់ កន្លែងអភិរក្សជលផល ស្មៅសមុទ្រ នាទីព្រៃកោងកាង ព្រែក ដែលជាដែននេសាទសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងភូមិចម្លងគោ ថ្មស ស្រែត្រាវ ស្រែថ្មី និងចំការលើ ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង មានទំហំ ១១ ២២០ ហិកតា និងមានកំណត់និយាមកាដូចមានចែង នៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងកន្លែងសហគមន៍នេសាទតាមាយ
- ខាងត្បូងទល់នឹងលំហរសមុទ្រ ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង
- ខាងកើតទល់នឹងលំហរសមុទ្រ ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង
- ខាងលិចទល់នឹងឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង។

**ខ. តំបន់គ្រប់គ្រងជលផល**

កន្លែងសហគមន៍នេសាទថ្មស ជាតំបន់គ្រប់គ្រងជលផលសមុទ្រ មានលំហរផ្ទៃទឹកសមុទ្រ ព្រែកចំនួន២ព្រែក នាទីព្រៃកោងកាង និងមានវាលភក់ ស្ថិតនៅក្នុងសហគមន៍នេសាទគឺៈ

- លំហរផ្ទៃទឹកសមុទ្រ ទំហំ ៩៧២៣ ហិកតា ពេញមួយឆ្នាំ
- ព្រែករាក់ធំ ទំហំ ២០ម x ៣០០ម ពេញមួយឆ្នាំ
- ព្រែកជ្រោយសំបួរ ទំហំ ២០ម x ៣៥០ម ពេញមួយឆ្នាំ
- នាទីព្រៃកោងកាង ទំហំ ២៨៨ ហិកតា ពេញមួយឆ្នាំ (ទឹកជោនាច)
- វាលភក់ ទំហំ ១២០៩ ហិកតា ពេញមួយឆ្នាំ (ទឹកជោនាច)។

**គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ**

- ក្នុងសមុទ្រមុខព្រែករាក់ធំ ទំហំ ១២៩ ហិកតា អភិរក្សព្រៃជលផល
- ក្នុងសមុទ្រមុខព្រែកជ្រោយសំបួរ ទំហំ ២៩៣ ហិកតា អភិរក្សព្រៃជលផល

**ឃ. ធនធានជលផល**

ប្រទេសកម្ពុជា ធនធានជលផលដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង និងសេដ្ឋកិច្ច ហើយធនធានជលផល បានផ្តល់ជាអាហារនិងមុខរបរនៃការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ ជាពិសេសអ្នកនេសាទវ័យចាស់។ តាមការបង្ហាញពីសហគមន៍ នេសាទកោះខ្យង បានឱ្យដឹងថា បច្ចុប្បន្នធនធាជលផលក្នុងសមុទ្រមិនមានការកើនឡើងទេ ដោយសារមានការប្រែប្រួលអាកាសធាតុ និងការប្រើប្រាស់មិនបានសមស្រប។

**ប្រភេទត្រីសមុទ្រ ៖** ត្រីក្តចិន ត្រីក្បក ត្រីក្តុក ត្រីស្លុង ត្រីក្រហម ត្រីផ្ទោង ត្រីឆ្លាម ត្រីបបែល ត្រីកាវ៉ាវ ត្រីប្រម៉ា ត្រីកាឡាំង ត្រីកន្តាំង ត្រីកន្ទុយរឹង ត្រីតុកកែ ត្រីអណ្តាតឆ្កែ ត្រីម្រេច ត្រីបាឃើ ត្រីអង្រៃ ត្រីទក់សមុទ្រ ត្រីប្លាធូ ត្រីអាំងកើយ ត្រីសេះ ត្រីសេក ជាដើម។ល។

**ប្រភេទវារីសត្វសមុទ្រ ៖** បង្គា បង្កង បង្កងកន្ទប បង្កងប៉ាក ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ ក្តាមប្រង់ មឹកគ្រែងឈាម ងាវ ងាវភក់ ងាវហួល ងាវស អណ្តើក កន្ទាយ បាលង្កកាស កញ្ជា អន្ទង់ ខ្ចឹង ផ្សោតស ផ្សោតខ្មៅ ។ល។

**ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ៖** ដើមកោងកាង ក្រញឹប អម្ពូ អម្ពា ក្របាញញី ក្របាញឈ្មោល ប៉ឹង ប្រាសាក់ ដើមបើស ឈើជ័រ ដើមក្លាយ អញ្ចរ ដើមឡេវអាវ ចាក ប្រង់ ដើមដូងទឹក ផ្កាថ្ម ស្មៅសមុទ្រ ។ល។

**៤. ការធ្វើនេសាទ**

**ក. អ្នកនេសាទ ៖**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៦០០នាក់ ស្រី២៣០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍នេសាទ២៥០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទមានចំនួន៥០នាក់ ។

**ខ. ឧបករណ៍នេសាទ ៖**

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន នាក់ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងត្រីក្បក | ម៉ែត្រ | ៥៤ | ១៥០០ម៉ែត្រ /គ្រួសារ | ក្រឡា៣,៥ស.មឡើង | ពេញរដូវនេសាទ |
| មងត្រីកាវ | ម៉ែត្រ | ៤៧ | ១០៥០ម៉ែត្រ/គ្រួសារ | ក្រឡា៧ស.មឡើង | ពេញរដូវនេសាទ |
| មងបង្កងកណ្តូប | ម៉ែត្រ | ៣០ | ១០៥០ម៉ែត្រ/គ្រួសារ | ក្រឡា៧ស.មឡើង | ពេញរដូវនេសាទ |
| មងត្រីសំប៉ាន់ | ម៉ែត្រ | ៣៥ | ១០៥០ម៉ែត្រ/គ្រួសារ | ក្រឡា៧ស.មឡើង | ពេញរដូវនេសាទ |
| មងត្រីកាវ៉ាវ | ម៉ែត្រ | ៣៥ | ១០៥០ម៉ែត្រ/គ្រួសារ | ក្រឡា៧ស.មឡើង | ពេញរដូវនេសាទ |
| មងត្រីកាតាំង | ម៉ែត្រ | ៣២ | ១០៥០ម៉ែត្រ/គ្រួសារ | ក្រឡា៧ស.មឡើង | ពេញរដូវនេសាទ |
| លបក្តាមថ្ម | លប | ៥៧ | ៥០០គ្រឿង/គ្រួសារ | ក្រឡា៦ស.មឡើង | ពេញរដូវនេសាទ |
| លបក្តាមសេះ | លប | ៤៧ | ២៥០គ្រឿង/គ្រួសារ | ក្រឡា៦ស.មឡើង | ពេញរដូវនេសាទ |

| | | | | | |
|---|---|---|---|---|---|
| សន្ទូចរនងត្រី | ផ្លែ | ៣៤ | ១០០-២០០ផ្លែ/គ្រួសារ | ផ្លែលេខ១២-១៦ | ឧសភាដល់ធ្នូ |
| រនងមឹកសំបកខ្យង | សំបក | ៣២ | ១៥០ផ្លែ/គ្រួសារ | ផ្លែលេខ១២-១៦ | ឧសភាដល់ធ្នូ |
| ឈិបរុញដោយដៃ | គ្រឿង | ២៣ | ១គ្រឿង/គ្រួសារ | ក្រឡា១,៥ស.មឡើង | ពេញរដូវនេសាទ |
| រាវគ្រែងឈាម | នាក់ | ៣៧ | ២០០នាក់ | - | ពេញរដូវនេសាទ |
| រាវងាវកក់ | នាក់ | ៤៣ | ២០០នាក់ | - | ពេញរដូវនេសាទ |
| លូកក្តាមថ្ម ជ័រ | នាក់ | ៨០ | ២០០នាក់ | - | ពេញរដូវនេសាទ |
| មងត្រី | ម៉ែត្រ | ៨៧ | ១០០០ម៉ែត្រ/គ្រួសារ | ក្រឡា ១០ ស.មឡើង | ឧសភាដល់ធ្នូ |
| លបត្រី | លប | ៤០ | ១០-២០លប/គ្រួសារ | ក្រឡា៦ស.មឡើង | ឧសភាដល់ធ្នូ |
| ទ្រូ | ទ្រូ | ៣ | ៩ទ្រូ/គ្រួសារ | - | ឧសភាដល់ធ្នូ |
| សំណាញ់ | វង់ | ១៥ | ១៥វង់/គ្រួសារ | ក្រឡា១,៥ស.មឡើង | ពេញរដូវនេសាទ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីនបន្តែត | ១៨៣ គ្រឿង | ៥០០-១០០០គីឡូក្រាម | ៦-២២ សេះ |
| ទូកម៉ាស៊ីនមានបាត | ៣៣០គ្រឿង | ៨០០-១៥០០គីឡូក្រាម | ២២-៣៥ សេះ |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងបង្គា | ម៉ែត្រ | ៩៦ | ៥០០ម៉ែត្រ/គ្រួសារ | ក្រឡា៣,៥ស.មឡើង | ពេញរដូវនេសាទ |
| មងត្រីកាម៉ុង | ម៉ែត្រ | ៤៣ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា៧ស.មឡើង | ពេញរដូវនេសាទ |
| មងក្តាម | ម៉ែត្រ | ២៥ | ៣០០ម៉ែត្រ/គ្រួសារ | ក្រឡា៦ស.មឡើង | វិច្ឆិកាដល់មករា |
| មងត្រីកន្តាំង | ម៉ែត្រ | ៣២ | ៥០០ម៉ែត្រ/គ្រួសារ | ក្រឡា៤ស.មឡើង | ពេញរដូវនេសាទ |
| មងបង្កងកណ្តូប | ម៉ែត្រ | ៣១ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា១០ស.មឡើង | តុលាដល់មេសាទ |
| មងត្រីបេកា | លប | ២៣ | ២៥០លប/គ្រួសារ | ក្រឡា៦ស.មឡើង | ពេញរដូវនេសាទ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីនបន្តែត | ១៨៣ គ្រឿង | ៥០០-១០០០គីឡូក្រាម | ៦-២២ សេះ |
| ទូកម៉ាស៊ីនមានបាត | ៣៣០គ្រឿង | ៨០០-១៥០០គីឡូក្រាម | ២២-៣៥ សេះ |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងបង្គា | ម៉ែត្រ | ១២ | ៥០០ម៉ែត្រ/គ្រួសារ | ក្រឡា៣,៥ស.មឡើង | ពេញរដូវនេសាទ |
| មងត្រីកាម៉ុង | ម៉ែត្រ | ១៥ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា៧ស.មឡើង | ពេញរដូវនេសាទ |
| មងក្តាម | ម៉ែត្រ | ១០ | ៣០០ម៉ែត្រ/គ្រួសារ | ក្រឡា៦ស.មឡើង | វិច្ឆិកាដល់មករា |
| មងត្រីកន្តាំង | ម៉ែត្រ | ៥ | ៥០០ម៉ែត្រ/គ្រួសារ | ក្រឡា៤ស.មឡើង | ពេញរដូវនេសាទ |
| មងបង្កងកណ្តូប | ម៉ែត្រ | ៨ | ៣៥០ម៉ែត្រ/គ្រួសារ | ក្រឡា១០ស.មឡើង | តុលាដល់មេសាទ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ២៥ គ្រឿង | ១០០០-១.៥០០គីឡូក្រាម | ២៤-៣៥ សេះ |

**គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ្រួសារអ្នកនេសាទ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចម្រុះ | ១០៥៧ គីឡូក្រាម | ១១៧៨ គីឡូក្រាម | ២២៣៥ គីឡូក្រាម |
| បង្គា | ៤៦០គីឡូក្រាម | ៤៥០ គីឡូក្រាម | ៩១០ គីឡូក្រាម |
| ក្តាម | ៣៣០ គីឡូក្រាម | ៤២០ គីឡូក្រាម | ៧៦០ គីឡូក្រាម |
| មឹក ខ្យង និងគ្រែងឈាម | ៩៨ គីឡូក្រាម | ១៥០ គីឡូក្រាម | ២៤៨ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

**ក. ទស្សនៈវិស័យ ៖**

សហគមន៍នេសាទថ្មស មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលសមុទ្រ ប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

**ខ. គោលបំណង ៖**

- ចូលរួមគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រ ដែលជាកន្លែងសហគមន៍នេសាទ នាទីព្រៃកោងកាង វាលភក់ និងកន្លែងនាទីទឹកជោរនាច
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

**គ. ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ**

**ផ្នែកទី១. ការអភិបាលកិច្ចនិងការគ្រប់គ្រង**

**គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ**

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ នៅចំណុចចុងពយ (ដីទំហំ៣០ម៉ែត្រ x ៣០ម៉ែត្រ) និយាមកា 327531, 1205374 ស្ថិតនៅក្នុងភូមិស្រែត្រាវ ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំជាមួយអាជ្ញាធរភូមិ ឃុំ និងអ្នកពាក់ព័ន្ធ | -មានការចូលរួម<br>-មានការគាំទ្រ | ២០០ | សហគមន៍នេសាទ ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |
| សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៨មx១២ម ធ្វើពីបេតុង គ្រឿងដែក | -ស.ន មានកន្លែងធ្វើការ<br>-មានលទ្ធភាពពេញលេញ | ២៥០០០ | សហគមន៍នេសាទ ស្ថាប័នពាក់ព័ន្ធ | កញ្ញា ២០២៥ | សីហា ២០២៨ |

| | | | | | |
|---|---|---|---|---|---|
| ប្រក់ហ្វីប្រូស៊ីម៉ង់ បន្ទប់មួយជ្រុងរៀប ជញ្ជាំងឥដ្ឋ ដោយតយ៉ាបបីជ្រុង និងមានបង្គន់អនាម័យ | ក្នុងការការពារ គ្រប់គ្រងកន្លែងសហគមន៍នេសាទ | | អង្គការដៃគូ | | |
| រៀបចំតបណ្ដាញអគ្គីសនី | មានថាមពលអគ្គីសនីធ្វើការ | ៨០០ | | | |
| តនិងរៀបចំប្រព័ន្ធទឹកស្អាត ស៊ីទែនជ័រ ១ ចំណុះ ៥ ០០០ លីត្រ | មានទឹកស្អាតប្រើប្រាស់ | ៦០០ | | | |
| ទិញសម្ភារសហគមន៍នេសាទ (តុ ទូ ក្ដារខៀន កៅអី កំព្យូទ័រ ព្រីនធើ) | មានសម្ភារសម្រាប់ស.ន ធ្វើការ | ១៥៥០ | | | |

(ម = ម៉ែត្រ, ស.ន = សហគមន៍នេសាទ)

### គ២- ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ

ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្ដាហ៍ទី១នៃខែ រៀងរាល់ខែឬត្រីមាស | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តន៍បន្ត<br>-លើកបញ្ហាប្រឈម តម្រូវការ | ៧២០ | -គណៈកម្មការ<br>-ក្រុមល្បាត | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចូលរួមប្រជុំជាមួយអាជ្ញាធរឃុំ ស្រុក ឬអង្គភាពពាក់ព័ន្ធ | -ទទួលព័ត៌មាន និងផ្ដល់របាយការណ៍លទ្ធផលការងារ<br>-បញ្ចូលផែនការណ៍ជាមួយផែនការអភិវឌ្ឍន៍ឃុំ<br>-មានដំណោះស្រាយ | ៦៥០ | -អាជ្ញាធរឃុំ<br>-គណៈកម្មការ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចូលរួមប្រជុំជាមួយបណ្ដាញស.ន ថ្នាក់ស្រុក ឬថ្នាក់ខេត្ត | | | -អាជ្ញាធរស្រុក/ខេត្ត<br>-បណ្ដាញស.ន | | |
| ចុះប្រជុំដើម្បីជម្រុញការចុះបញ្ជីទូកម៉ាស៊ីន ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធ ជាប្រចាំ | - ចុះបញ្ជីទូកម៉ាស៊ីនគ្រប់ចំនួន<br>- ទូកម៉ាស៊ីនធ្វើនេសាទបានដាក់ប្រព័ន្ធតាមដាន<br>-បទល្មើសជលផលថយចុះ | ៦០០ | គណៈកម្មការ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>ស្ថាប័នពាក់ព័ន្ធ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចុះអនុវត្តន៍សកម្មភាពការប្រមូលព័ត៌មាន ការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | -មានព័ត៌មានច្បាស់លាស់<br>-រៀបចំផែនការបានត្រឹមត្រូវ<br>-ការគ្រប់គ្រងស.នបានល្អ | ៩០០ | -គណៈកម្មការ<br>-សមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| -សម្ភារការិយាល័យ<br>- LCD with Screen<br>-ទិញក្រដាស់ ប៊ិច ព្រីនឯកសារ កូពី<br>-ការទំនាក់ទំនង | មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់ | ២០០០ | គណៈកម្មការ | កញ្ញា ២០២៥ | សីហា ២០២៨ |

(ស.ន = សហគមន៍នេសាទ)

### គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយស្តីពី ៖<br>-ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីសហគមន៍កសិកម្ម ឯកសារគតិយុត្តិនានាពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងស.ន និងផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ<br>-ការរៀបចំនិងទុកដាក់សម្រាម<br>-បទពិសោធន៍នានាទទួលបាន | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ<br>-ផលត្រីនៅក្នុងសហកមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឱ្យជីវភាពធូរធារ | ២៥៨០ | គណៈកម្មការ, សមាជិកស.ន និងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូ | ឧសភា-ធ្នូ/ រៀងរាល់ឆ្នាំ | |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៦០ | | កញ្ញា ២០២៥ | សីហា ២០២៨ |
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានា | | ៤៥០ | | | |
| ផ្សព្វផ្សាយដល់សមាជិកសហគមន៍នេសាទ ដើម្បីចុះបញ្ជីទូកម៉ាស៊ីន | សមាជិកសហគមន៍នេសាទបានចុះបញ្ជីទូកម៉ាស៊ីនតាមច្បាប់ | ៤៥០ | | កញ្ញា ២០២៥ | សីហា ២០២៨ |
| ២.ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល ៖<br>-កំណត់ហេតុ និងរបាយការណ៍<br>-គម្រោងស្នើសុំថវិកានិងការគ្រប់គ្រងថវិកាសហគមន៍នេសាទ | គណៈកម្មការ និងសមាជិកស.ន បានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ១៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | កញ្ញា ២០២៥ | សីហា ២០២៨ |
| វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈកម្មការស.ន (២នាក់) | ៣៦០ | គណៈកម្មការស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន ដោយការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | គណៈកម្មការសហគមន៍នេសាទបានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៨០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | | |
| វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលនិងដោះស្រាយទំនាស់ | | ៤០០ | គណៈកម្មការជំនាញជលផល | | |

(ស.ន = សហគមន៍នេសាទ)

### គ.៤ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ គឺរៀបចំឡើងដោយគិតគូរនូវប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| កន្លែងនេសាទសហគមន៍ថ្មស | ពេញរដូវនេសាទ | មងត្រីក្បក | ក្រឡា ៣,៥ស.មឡើង | ៥០០ម/គ្រួសារ | គណៈកម្មការ និងសមាជិកសហគមន៍នេសាទ |
| | | មងត្រីឆ្តង | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីក្អុក | ក្រឡា ៩ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីអណ្តាតឆ្កែ | ក្រឡា ៥,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីចាប | ក្រឡា ៦ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបបែល | ក្រឡា ១៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីព្រលូស | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីប្រឧប ឬត្រីកាម៉យ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាប៉ាស់ ឬត្រីដូរអង្ករ | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីក្បាន្ត | ក្រឡា ៣ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីផ្ទោង | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកន្តាំង | ក្រឡា ៤ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងក្តាម | ក្រឡា ៨ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងប៉ាកាំង ឬបង្កងកន្ទប | ក្រឡា ៣ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាម៉ុង | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកន្ទុយរឹង | ក្រឡា ៤,៨ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាវ៉ាវ | ក្រឡា ៧ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបេកា | ក្រឡា ៨ ស.មឡើង | ៣០០ម/គ្រួសារ | |
| | | មងត្រីសំប៉ាន | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីគួន | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបង្គា១ជាន់ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបង្គា៣ជាន់ | ក្រឡា ៣,៥ ស.មឡើង | ៣០០ម/គ្រួសារ | |
| | | មងហ៊ុម | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | លបមឹក | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបក្តាម | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបបង្គា | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបខ្យង | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបត្រី | ក្រឡា ៦ ស.មឡើង | ២០លប/គ្រួសារ | |
| | | លបត្រីតុកកែ | ក្រឡា ៦ ស.មឡើង | ២០លប/គ្រួសារ | |
| | | លបប្រើសច្រើន/កន្ទុយកណ្តុរ | ក្រឡា ៣ ស.មឡើង | ២០លប/គ្រួសារ | |
| | | អួនត្រីស | ក្រឡា ២,៥ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនត្រីកាឡេងតេង | ក្រឡា ១,៥ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនហ៊ុមគៀនច្រាំង | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនខ្វរ ឬមងខ្វរ | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ថ្មស | ពេញរដូវនេសាទ | អួនកេវ ឬមងកេវ | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | គណៈកម្មការ និងសមាជិកសហគមន៍នេសាទ |
| | | សន្ទូចរនងត្រី | មិនកំណត់ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចរនងបបែល | មិនកំណត់ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចរនងមឹក | ផ្លែលេខ១-៤ | ៥០០ផ្លែ/គ្រួសារ | |
| | | រនងធ្លាក់មឹក | - | ៥០០គ្រ/គ្រួសារ | |
| | | សន្ទូចត្រីបេកា | - | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចមឹក | ផ្លែលេខ១-៤ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចដៃ | មិនកំណត់ | មិនកំណត់ | |
| | | សន្ទូចបបក់ | មិនកំណត់ | មិនកំណត់ | |
| | | ឈិបរុញដោយដៃ | ក្រឡា ១,៥ ស.មឡើង | មិនកំណត់ | |
| | | រាវគ្រែងឈាម | មិនកំណត់ | មិនកំណត់ | |
| | | រាវងាវភក់ | មិនកំណត់ | មិនកំណត់ | |
| | | លូកក្តាមថ្ម ជំរ | មិនកំណត់ | មិនកំណត់ | |
| | | សំណាញ់ | ក្រឡា ១,៥ ស.មឡើង | មិនកំណត់ | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ, គ្រ = គ្រាប់)

**គ៥-ផែនការទប់ស្កាត់បទល្មើសជលផល**

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយៈ<br>-តាមមេក្រូ ២ដង/ឆ្នាំ<br>-បិទឯកសារ ១ដង/ឆ្នាំ<br>-ចែកឯកសារ<br>-ប្រជុំផ្សព្វផ្សាយ ១ដង/ឆ្នាំ សីហា/រៀងរាល់ឆ្នាំ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទនិងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ<br>-កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ | ១០០០ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រជុំប្រចាំខែ ឬឆមាស (មិថុនានិងធ្នូ/រៀងរាល់ឆ្នាំ) | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្តន៍ការងារ | ៣៦០ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>អង្គភាពពាក់ព័ន្ធ | | |
| អនុវត្តន៍ផែនការៈ (រៀបចំកំលាំងចុះល្បាតដល់ទីកន្លែង ដោយទំនាក់ទំនង និងឬសហការជាមួយ អាជ្ញាធរមូលដ្ឋាន និងឬ អង្គភាពពាក់ព័ន្ធ) (៤ដង/ខែ = ១៤៤/ដង) | -បទល្មើសជលផលថយចុះ និងឈានទៅលុបបំបាត់ ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកសហគមន៍នេសាទធូរធារ | ១០៣៦៨ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>ស្ថាប័នពាក់ព័ន្ធ<br>អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |

| | | | | | |
|---|---|---|---|---|---|
| មធ្យោបាយនិងសម្ភារ -សាំងឬម៉ាស៊ីតនិងប្រេងបាត -អាវ ស្បែកជើង មួក អាវភ្លៀង អាវពោង ពិល អាយកូម ម៉ាស៊ីនថត កែវយិត កាតទូរស័ព្ទ | មានលទ្ធភាពចុះល្បាតដោយ មានប្រសិទ្ធិភាព | ៣៣៤៦ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ទិញអូប័រនិងម៉ាស៊ីន៤០សេះ ចំនួន១គ្រឿង | មានមធ្យោបាយចុះល្បាត | ៦០០០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | | |
| គៀងគរថវិកាក្នុងការ ឧបត្ថម្ភ ឬបដិភាគដល់ ប្រជានេសាទដែលឈប់ឬ ផ្លាស់ប្តូរការប្រើឧបករណ៍ នេសាទខុសច្បាប់ឬប្រគល់ ជូននូវប្រភេទកំពុងរងគ្រោះ | កាត់បន្ថយការប្រើប្រាស់ឧបករណ៍ នេសាទខុសច្បាប់ | ៥០០០ | | កញ្ញា ២០២៥ | សីហា ២០២៨ |

**គ.៦ ផែនការកែលម្អកន្លែងសហគមន៍នេសាទ**

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ដែននេសាទ | ទំហំ (ហិកតា) | ទំហំដែល ត្រូវកែលម្អ | សកម្មភាព | ប៉ាន់ប្រមាណ តម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| កន្លែងនេសាទ សហគមន៍ ថ្មស | ១១២២០ | ១១២២០ ហិកតា | ប្រជុំផ្សព្វផ្សាយដល់អង្គភាព អាជ្ញាធរ ស្ថាប័ន និងអ្នកពាក់ព័ន្ធ | ១០០ | សីហា ២០២៥ | កក្កដា ២០២៨ |
| | | | សាងសង់ផ្ទាំងប៉ាណូផ្សព្វផ្សាយ ២ផ្ទាំង ២,៥០ ម x ២ម គ្រឿងដែក(ដែកមូល) | ១២០០ | | |
| | | | ស្លាកសញ្ញាផ្សព្វផ្សាយ១០ផ្ទាំង១,២មx១ម គ្រឿងដែក(ដែកមូល) | ២០០០ | | |
| | | | កំណត់ទីតាំងតាមនិយាមកា ដើម្បីបោះ បង្គោលព្រំប្រទល់សហគមន៍នេសាទ លើគោក ៣០ បង្គោល ធ្វើពីបេតុង | ៤៥០០ | | |
| | | | កំណត់ទីតាំងតាមនិយាមកានិងបោះបង្គោល ព្រំប្រទល់សហគមន៍នេសាទក្នុងទឹក ចំនួន ៨បង្គោល(មូល)ធ្វើពីបេតុងទំហំ០,៣មx៨ម | ៨០០០ | | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

**គ.៧ ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ**

ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផល ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែន នេសាទ | ទំហំ ត្រូវអភិរក្ស (ហ.ត) | ប្រភេទនៃ ការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណ តម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| អភិរក្សជលផល<br>ព្រៃករាក់ធំ<br>១២៩ ហិកតា<br>327485-1209788<br>327518-1210885<br>328706-1210701<br>328655-1209618 | ១២៩ | -ព្រៃកោងកាង<br>-ក្ដាមជ័រ<br>-ជីវចម្រុះ | ផ្សព្វផ្សាយពីកន្លែងអភិរក្សជលផលនិងហាមឃាត់ដល់ប្រជាពលរដ្ឋ ឱ្យបានទូលំទូលាយ | ៨០០ | កញ្ញា<br>២០២៥ | សីហា<br>២០២៨ |
| | | | រកទីតាំងដាក់ស្តែងតាមនិយាមកា | ៦០០ | | |
| | | | បោះបង្គោលព្រំកន្លែងអភិរក្សជលផលធ្វើពីគ្រឹះស៊ីម៉ង់បង្គោលដែក(សាជី) ចំនួន៤បង្គោល | ២៨០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៦០០ | | |
| | | | សង់ប៉មយាមការពារកន្លែងអភិរក្សភ្ជាប់ជាមួយបង្គោលធ្វើពីគ្រឿងដែក ប្រក់ហ្វីប្រូស៊ីម៉ង់ | ១៥០០ | | |
| | | -ត្រី ផ្សោត<br>-ជីវចម្រុះ | ចុះសិក្សាប្រមូលព័ត៌មាន | ៥០០ | កញ្ញា<br>២០២៥ | សីហា<br>២០២៨ |
| | | | ប្រជុំផ្សព្វផ្សាយពីកន្លែងសាងសង់ជម្រកសិប្បនិម្មិត | ៥០០ | | |
| | | | ពង្រាយប្រអប់ជម្រកត្រីសិប្បនិម្មិតធ្វើពីបេតុងចំនួន ៥០ ប្រអប់ | ៥០០០ | | |
| អភិរក្សជលផល<br>ព្រៃកជ្រោយសំបូរ<br>២៩៣ ហិកតា<br>327774-1208140<br>329267-1208152<br>329236-1206349<br>327708-1206053 | ២៩៣ | -គ្រែងឈាម<br>-ជីវចម្រុះ | រកទីតាំងដាក់ស្តែងតាមនិយាមកា | ៦០០ | កញ្ញា<br>២០២៥ | សីហា<br>២០២៨ |
| | | | បោះបង្គោលព្រំកន្លែងជម្រកសុវត្ថិភាពធ្វើពីគ្រឹះស៊ីម៉ង់បង្គោលដែក(សាជី) ចំនួន៤បង្គោល | ២៨០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៦០០ | | |
| | | | សង់ប៉មយាមការពារកន្លែងអភិរក្សភ្ជាប់ជាមួយបង្គោលធ្វើពីគ្រឿងដែក ប្រក់ហ្វីប្រូស៊ីម៉ង់ | ១៥០០ | | |
| | | | ពង្រាយប្រអប់ជម្រកត្រីសិប្បនិម្មិតធ្វើពីបេតុងចំនួន ៥០ ប្រអប់ | ៥០០០ | | |

### គ.៨ ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្ដាមសេះពងរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្ដាមសេះពង ត្រូវរៀបចំឡើងដើម្បីបង្កើនផលស្តុកធម្មជាតិ នៃធនធានជលផល ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ (ហិកតា) | ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ក្នុងកន្លែងសហគមន៍នេសាទថ្មស<br>328343-1206086<br>328469-1206085<br>328472-1205847<br>328349-1205842 | ៣<br>សាកល្បងជំហានទី១ទំហំ ៥០មx៥០ម | -ក្ដាមសេះ<br>-ស្មៅសមុទ្រ<br>-ជីវចម្រុះ | ផ្សព្វផ្សាយដល់ប្រជានេសាទឱ្យបានទូលំទូលាយដើម្បីប្រមូលក្ដាមសេះពង | ៣៦០ | កញ្ញា<br>២០២៥ | សីហា<br>២០២៨ |
| | | | ជួសជុលស្ថានីយ៍១កន្លែងនិងស្ពានដើរជុំវិញស្ថានីយ៍ធ្វើពីឈើ និងសម្ភារជាង | ៥៥០០ | | |
| | | | បោះបង្គោលព្រំកន្លែងការពារក្ដាមសេះ និងព័ទ្ធស្បៃមុង | ៥០០ | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ពង្រាយប្រអប់ថ្មបេតុងត្រីសិប្បនិម្មិត ធ្វើពី ចំនួន១០ប្រអប់ថ្មបេតុង | ៤០០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ២០០ | | |
| | | | ព្រលែងកូនក្តាម និងមេក្តាមពង | ៥០០ | | |
| | | | ទិញឧបករណ៍សម្ភារគាំទ្រសកម្មភាពភ្ញាស់កូនក្តាមសេះ | ៥០០ | | |
| | | | ថែទាំ និងប្រមូលផល | ១០០ | | |

(ម = ម៉ែត្រ)

## ឥ.៩ ផែនការគ្រប់គ្រងព្រៃកោងកាង

ផែនការគ្រប់គ្រងកោងកាង ត្រូវបានរៀបចំឡើងវិញ ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|---|
| ព្រៃកោងកាងដែលមានស្រាប់ក្នុងកន្លែងសហគមន៍នេសាទ | ២៨៨ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ | ប្រជុំ | ៣០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | រកចំណុចទីតាំងដាក់ស្តែងតាមនិយាមកា | | ២០០ | | |
| | | | ដាក់ស្លាកសញ្ញាដែនទីព្រៃកោងកាង១ស្លាក ២,៥ម x ១,៥ម ធ្វើពីគ្រឿងដែក ចាក់បេតុង | | ៤០០ | | |
| | | | ថែរក្សា ការពារ | | | | |
| ផ្ទៃដីដាំព្រៃកោងកាងស្ថិតក្នុងកន្លែងនេសាទសហគមន៍ | ១០៩ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ | ប្រជុំ | ៣០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | រកចំណុចទីតាំងដាក់ស្តែងតាមនិយាមកា | | ២០០ | | |
| | | | ដាក់ស្លាកសញ្ញាដែនទីព្រៃកោងកាង១ស្លាក ២,៥ម x ១,៥ម ធ្វើពីគ្រឿងដែក ចាក់បេតុង | | ៨០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | រៀបចំថ្នាលបណ្តុះកូនកោងកាង បង្គោលឈើ និងស្បៃ ១០ម x ២០ម | | ១០០០ | | |
| | | | បណ្តុះ ដាំ និងថែទាំដើមកោងកាងកាង១០ហិកតា ៥០០០០ដើម (១ហិកតា x ៥០០០ដើម) | | ៥០០០០ | | |
| | | | ដាំកូនកោងកាងចំនួន១៥នាក់x៨,៥ដុល្លារ/ថ្ងៃ | | ៣០០០ | | |
| | | | ថែទាំដើមកោងកាង រយៈពេល៣ខែ ៤នាក់ x ១០ដុល្លារ/ថ្ងៃ,២ថ្ងៃ/អាទិត្យ | | ១០០០ | | |
| | | | ពី៣ខែដល់៦ខែ ៤នាក់ x ១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/អាទិត្យ | | ១០០០ | | |
| | | | ពី៦ខែឡើងទៅ ៤នាក់x១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/ខែ | | ១២០០ | | |

(ម = ម៉ែត្រ)

## ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ

### គ១០- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១. ផែនការបណ្តុះបណ្តាល | | | | | |
| ចិញ្ចឹមគ្រែងឈាម | -មានចំណេះដឹងចិញ្ចឹមគ្រែងឈាម ក្តាមថ្ម និងងាវភក់<br>-យកទៅអនុវត្តជាក់ស្តែងបាន | ៩០០ | គណៈកម្មការនិងសមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចិញ្ចឹមក្តាមថ្ម | | ៩០០ | | | |
